ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានកិច្ចការរដ្ឋបាល
ចូល
លេខ........៤១២២
ថ្ងៃទី..០៧..១០..១៣.
បញ្ជូន.................................

# ព្រះរាជក្រឹត្យ

នស/រកត/១០១៣/៩៥៦

## ស្តីពី
## ការរំសាយឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
## និង ក្រុមប្រឹក្សាកំណែទម្រង់ចំណុះឱ្យឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១.-**

ត្រូវបានរំសាយឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និង ក្រុមប្រឹក្សាកំណែទម្រង់ពាក់ព័ន្ធផ្សេងទៀត ចំណុះឱ្យឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។

**មាត្រា ២.-**

ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និង ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ព្រមទាំងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងការបង្កើតក្រុមប្រឹក្សាចំណុះឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋផ្សេងទៀត ត្រូវទុកជានិរាករណ៍ ។

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

**មាត្រា ៣.-**

ការងារកំណែទម្រង់រដ្ឋបាល ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងមុខងារសាធារណៈ ។

ការងារកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងយុត្តិធម៌ ។

ការងារកំណែទម្រង់កងយោធពលខេមរភូមិន្ទ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងការពារជាតិ ។

ការងារគោលនយោបាយដីធ្លី ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ។

**មាត្រា ៤.-**

ត្រូវបានផ្ទេរ និង ធ្វើសមាហរណកម្មអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ទៅក្នុងក្រសួងមុខងារសាធារណៈ ។

ត្រូវបានផ្ទេរ និង ធ្វើសមាហរណកម្មអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ទៅក្នុងក្រសួងយុត្តិធម៌ ។

**មាត្រា ៥.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧រស.១៣១០.៩៧០

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០១៣*

លេខៈ៩៤៥ស.ណ
សំណៅចម្លងមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ .ថ្ងៃទី ០៤ ខែ ១៣ ឆ្នាំ២០១៣
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុយ សុខា

លេខ ៦៦៥ ចលេ.កសក
បានចម្លងត្រឹមត្រូវតាមសំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ១៦ ខែ ១៧ ឆ្នាំ២០១៣
ត.ប រដ្ឋមន្ត្រី
អគ្គលេខាធិការ

ឈ្មោះ ...

កន្លែងទទួល:
- គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ឯកសារ កាលប្បវត្តិ